ធ្វើជាអ្នកប្រើប្រាស់ការថែទាំសុខភាពដ៏ឆ្លាតវៃ

# ការឆបោក និងការបោកប្រាស់នៃជំងឺ COVID-19



នៅគ្រប់ពេលដែលមានវិបត្តិសុខភាព ជនឆបោកឆ្លៀតឱកាសបោកប្រាស់ប្រាក់របស់ប្រជាជនយ៉ាងឆាប់រហ័ស។ ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកលកូរ៉ូណា ជនឆបោកកំពុងប្រើប្រាស់ទូរសព្ទស្វ័យប្រវត្តិ (robocalls) ការប្រកាសលើបណ្ដាញសង្គម និងអ៊ីមែលដើម្បីទាញផលប្រយោជន៍ពីការភ័យខ្លាច ការថប់បារម្ភ និងភាពច្របូកច្របល់អំពីជំងឺ COVID-19។ ឧក្រិដ្ឋជនកំពុងលក់របស់ដែលមិនមាន ប្រសិទ្ធភាព គិតលុយលើរបស់ដែលឥតគិតថ្លៃ(Free) និងកំពុងលួចព័ត៌មានផ្ទាល់ខ្លួន។ ចូរប្រុងប្រយ័ត្ន ចំពោះការឆបោកទាំងនេះ៖

## ការឆបោកនៃការធ្វើតេស្តជំងឺ COVID-19

- **ឧបករណ៍ធ្វើតេស្តនៅផ្ទះដែលមានលក់នៅតាមផ្លូវ ឬពីផ្ទះមួយទៅមួយគឺជាការឆបោក។** គិតត្រឹមថ្ងៃទី 2 ខែមិថុនាឆ្នាំ 2020 ឧបករណ៍ធ្វើតេស្តនៅផ្ទះអាចរកបានលុះត្រាតែមានការបញ្ជាទិញពីគ្រូពេទ្យ ហើយវាត្រូវបានដឹកជញ្ជូនទៅដល់អ្នកជំងឺតាមប្រៃសណីយ៍។
- **ការធ្វើតេស្តរកជំងឺកូរ៉ូណាគឺមានដោយឥតគិតថ្លៃ** សម្រាប់មនុស្សគ្រប់គ្នានៅក្នុងខោនធី LA *ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ឡើយ*។ បើសិនជាអ្នកឈឺ ឬមានការព្រួយបារម្ភអំពីជំងឺ COVID-19 ចូរពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក។ អ្នកក៏អាចទទួលបានការធ្វើតេស្តឥតគិតថ្លៃដោយចូលទៅកាន់ covid19.lacounty.gov/testing ឬដោយទូរសព្ទទៅលេខ 2-1-1។
- **ស្វែងយល់អំពីការធ្វើតេស្តជំងឺ COVID-19 នៅ** ទីនេះ។

## ការតាមដានអំពីការឆបោក

- **ជនឆបោក អាចទូរសព្ទ ទៅជួប សរសេរសំបុត្រ ឬអ៊ីមែលដើម្បីព្យាយាមទទួលបានព័ត៌មាន។** នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងទូរសព្ទ ផ្ញើអ៊ីមែល ឬសរសេរសំបុត្រទៅកាន់អ្នកដែលមានជំងឺ COVID-19 និងមនុស្សដែលពួកគេអាចនឹងប៉ះពាល់។ ការទូរសព្ទពី Public Health នឹងបង្ហាញ បង្ហាញ "LA PublicHealth" ឬ 1-833-641-0305 ជា ID របស់អ្នកទូរសព្ទទៅ ហើយពួកគេនឹងមិនសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍ ស្នើសុំលេខ សន្តិសុខសង្គម ឬស្នើសុំប្រាក់ឡើយ។ បើសិនជាអ្នកទទួលទូរសព្ទ ឬសារពី Public Health សូមឆ្លើយតប ឬទូរសព្ទមកវិញដើម្បីជួយយើងគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងខោនធី Los Angeles។

## ការព្យាបាលជំងឺ COVID-19 ក្លែងក្លាយ និង "ថ្នាំទិព្វ" (miracle cures)

- **ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយសម្រាប់ថ្នាំបំប៉ន និង "ការព្យាបាល" អាចអះអាងខុសការពិតថាបង្ការ ឬព្យាបាលជំងឺ COVID-19។**
- **មិនមាន "បញ្ជីរង់ចាំវ៉ាក់សាំង" ទេ។** កុំឲ្យជនឆបោកយកប្រាក់របស់អ្នក ដើម្បីបានឈ្មោះនៅក្នុងបញ្ជីរង់ចាំវ៉ាក់សាំងក្លែងក្លាយ។
- **ចូរប្រឹក្សាយោបល់ជាមួយគ្រូពេទ្យ ឬ អ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណផ្សេងទៀតជានិច្ច** មុននឹងប្រើថ្នាំ ឬផលិតផលសុខភាពណាមួយ។

### ទទួលជំនួយ

- **ស្វែងរកគ្រូពេទ្យ៖** ទូរសព្ទទៅលេខ 2-1-1 ដែលជាខ្សែទូរសព្ទព័ត៌មានខោនធី LA ឬចូលទៅកាន់ គេហទំព័រ 211LA។
- **ស្វែងរកធនធានដូចជាម្ហូបអាហារ និងការផ្គត់ផ្គង់សំខាន់ៗផ្សេងទៀត៖** ទូរសព្ទទៅលេខ 2-1-1 ឬចូលទៅកាន់ គេហទំព័រ 211LA ឬ គេហទំព័រធនធាន របស់ Public Health។
- **រាយការណ៍ពីការឆបោកជំងឺ COVID-19 ដែលអាចមាន និងទទួលជំនួយក្នុងការយកប្រាក់របស់អ្នកមកវិញ៖** ទាក់ទងនាយកដ្ឋានកិច្ចការអ្នកប្រើប្រាស់ និងអាជីវកម្មរបស់ខោនធី LA (LA County Department of Consumer and Business Affairs)៖ dcba.lacounty.gov ឬ 800-593-8222។
- **រាយការណ៍ពីការអះអាងដែលគួរឲ្យសង្ស័យ ដែលបានធ្វើឡើងអំពីការធ្វើតេស្ត ឬផលិតផលព្យាបាល៖** រាយការណ៍ទៅកាន់ FTC នៅ ftc.gov/complaint

## ការឆបោកអំពីសែកប្រាក់ឧបត្ថម្ភ (Stimulus check)

- **អ្នកនឹងមិនត្រូវបានស្នើឲ្យបង់ប្រាក់ជាមុនដើម្បីទទួលបានសែកប្រាក់ឧបត្ថម្ភសហព័ន្ធ** ការបង់ប្រាក់ធានារ៉ាប់រងការគ្មានការងារធ្វើ ឬការបង់ប្រាក់ប្រចាំខែសម្រាប់សន្តិសុខសង្គមរបស់អ្នកឡើយ។
- **ស្វែងយល់បន្ថែមនៅ** ទីនេះ អំពីរបៀបចៀសវាងការឆបោកក្នុងករណីសែកប្រាក់ឧបត្ថម្ភរបស់អ្នក។

## ការដំឡើងតម្លៃទំនិញក្នុងអំឡុងពេលមានជំងឺរាតត្បាតសកល COVID-19

- **កុំបង់ថ្លៃឲ្យលើសពីអ្វីដែលអ្នកគួរបង់សម្រាប់ការផ្គត់ផ្គង់ និងសេវាកម្ម។** ការដំឡើងតម្លៃទំនិញគឺនៅពេលដែលអ្នកត្រូវបានគេស្នើឲ្យបង់ថ្លៃលើសពីតម្លៃធម្មតា 10% ឬច្រើនជាងនេះសម្រាប់ទំនិញ និងសេវាកម្មចាំបាច់។
- **ការដំឡើងតម្លៃទំនិញគឺជាអំពើខុសច្បាប់។** ស្វែងយល់បន្ថែម ឬរាយការណ៍ពីការដំឡើងតម្លៃទំនិញនៅ ទំព័រ របស់ខោនធី LA។

## "អ្នកជួយ" ក្លែងក្លាយដែលផ្តល់ការដឹកជញ្ជូន និងធ្វើកិច្ចការអ្វីមួយ

**ជនឆបោកធ្វើជាជួយ ខណៈដែលអ្នកនៅផ្ទះក្នុងអំឡុងជំងឺ COVID-19 បន្ទាប់មករត់គេចខ្លួនជាមួយប្រាក់របស់អ្នក។**

- រៀបចំឲ្យដឹកជញ្ជូនការផ្គត់ផ្គង់ចាំបាច់ដូចជាម្ហូបអាហារ និងថ្នាំទៅអ្នកដោយមិត្តភក្តិ ឬអ្នកជិតខាងដែលបានទុកចិត្ត រៀបចំការដឹកជញ្ជូនជាមួយក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះល្អ ឬប្រើប្រាស់សេវាកម្មមួយក្នុងចំណោមសេវាកម្មឥតគិតថ្លៃខាងក្រោម។
- **ស្គាល់ថាអ្នកកំពុងទិញពីអ្នកណា។** អ្នកលក់តាមអនឡាញ មួយចំនួនអះអាងថាមានផលិតផលកំពុងមានតម្រូវការខ្ពស់ដូចជាផលិតផលសម្អាត ឬឱសថ នៅពេលដែលពួកគេមិនមាន។ បញ្ជាទិញដោយផ្ទាល់ពីហាង ឬឱសថស្ថាន និងសាកសួរអំពីការដឹកជញ្ជូនដោយឥតគិតថ្លៃ។
- **ស្វែងយល់អំពីជម្រើសឥតគិតថ្លៃ និងមានតម្លៃទាប។** អ្នកអាចទទួលការដឹកជញ្ជូនឥតគិតថ្លៃតាមរយៈកម្មវិធីដឹកជញ្ជូនសេវាកម្មចាំបាច់ (Critical Service Delivery Program) របស់ខោនធី LA ឬទូរសព្ទទៅលេខ 888- 863-7411។
- **កម្មវិធីមួយចំនួនកំពុងផ្តល់អាហារឥតគិតថ្លៃជារៀងរាល់ថ្ងៃ។** ចុះឈ្មោះក្នុងកម្មវិធីដឹកជញ្ជូន Great Plates របស់ខោនធី LA ឬកម្មវិធីម្ហូបអាហារជនចាស់ជរារបស់ទីក្រុង (City's Senior Meals Program) តាមអនឡាញ ឬដោយទូរសព្ទទៅលេខ (800) 510-2020។សម្រាប់ជម្រើសនៅក្នុងតំបន់របស់អ្នក សូមចូលទៅកាន់ 211LA ឬទូរសព្ទទៅលេខ 211។

## សប្បុរសធម៌ក្លែងក្លាយ

- មនុស្សជាច្រើនចង់ជួយអ្នកដទៃនៅក្នុងសហគមន៍ដែលកំពុងរងគ្រោះ និងដែលអាចបាត់បង់ការងារដោយសារមេរោគកូរ៉ូណា។ គួរឲ្យស្តាយ មនុស្សដែលចង់ជួយទាំងនេះអាចត្រូវបានកេងចំណេញដោយជនឆបោកដែលសម្បូរដោយកលល្បិច។
- **ធ្វើការស្រាវជ្រាវដោយខ្លួនឯងនៅពេលទាក់ទងនឹងការបរិច្ចាគ**។
- កុំឲ្យអ្នកណាជំរុញឲ្យអ្នកប្រញាប់ធ្វើការបរិច្ចាគ និងចូរពិនិត្យមើលថាតើសប្បុរសធម៌នោះស្របច្បាប់ឬក៏អត់ ដោយស្វែងរក CA Attorney General's Registry of Charitable Trusts។ ទទួលបានគន្លឹះបន្ថែមអំពីការបរិច្ចាគយ៉ាងឆ្លាតវៃនៅ **ftc.gov/charity**

## ចោរលួចអត្តសញ្ញាណវេជ្ជសាស្ត្រ និងការឆបោកលួចព័ត៌មាន

- **ជនឆបោកព្យាយាមលួចលេខធានារ៉ាប់រង ព័ត៌មានផ្ទាល់ខ្លួន និងប្រាក់។** កុំផ្តល់លេខធានារ៉ាប់រង Medicare ឬ Medi-Cal ឬលេខសន្តិសុខសង្គម ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតរបស់អ្នកតាមទូរសព្ទ អ៊ីមែល ឬសារជាអក្សរក្នុងការឆ្លើយតបទៅការទាក់ទងដែលបានស្នើសុំ (មិនបានអញ្ជើញ ឬមិនស្គាល់)។
- **ភ្នាក់ងាររដ្ឋាភិបាលដូចជា Medicare, Medi-Cal, សន្តិសុខសង្គម និង IRS** នឹងមិនទូរសព្ទទៅអ្នកដើម្បីលក់អ្វីមួយឲ្យអ្នក ឬធ្វើការ "ចុះឈ្មោះ" អ្នកតាមទូរសព្ទឡើយ។ ពួកគេនឹងមិនទាក់ទងអ្នកសម្រាប់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកឡើយ លុះត្រាតែអ្នកបានផ្តល់ការអនុញ្ញាតឲ្យពួកគេជាមុន។ ពួកគេក៏នឹងមិនទៅផ្ទះរបស់អ្នក លុះត្រាតែពួកគេកំពុងបម្រើការឲ្យជំរឿនឆ្នាំ 2020 (2020 Census)។ នេះគឺជាគន្លឹះមួយចំនួនអំពីរបៀប ទប់ស្កាត់ការបោកប្រាស់ Medicare និងការបោកប្រាស់សន្តិសុខសង្គម (Social Security) ដែលទាក់ទងនឹងមេរោគកូរ៉ូណា។
- **ដាក់ទូរសព្ទចុះសម្រាប់ទូរសព្ទស្វ័យប្រវត្តិ**មកពី "ភ្នាក់ងាររដ្ឋាភិបាល" បើសិនជា ទូរសព្ទស្វ័យប្រវត្តិខុសច្បាប់ ទាំងនេះបន្តចូរសាកសួររកព័ត៌មានរបស់ពួកគេ ដើម្បីឲ្យអ្នកអាចរាយការណ៍ពីពួកគេទៅកាន់ គណៈកម្មការពាណិជ្ជកម្មសហព័ន្ធ (Federal Trade Commission) បាន។ អ្នកក៏អាចកាត់បន្ថយចំនួនទូរសព្ទអចលនទ្រព្យដោយចូលរួមក្នុង "បញ្ជីកុំទូរសព្ទ (Do Not Call List)ផងដែរ។"

### តាមដានស្ថានការណ៍ - ជាមួយព័ត៌មានដែលអាចទុកចិត្តបាន

ចូរប្រុងប្រយ័ត្នចំពោះព័ត៌មានក្លែងក្លាយ និងការបោកបញ្ឆោតក៏ដូចជាការឆបោកជុំវិញជំងឺ COVID-19

**បច្ចុប្បន្នភាពមេរោគកូរ៉ូណា**

- ចូលទៅកាន់ ph.lacounty.gov/media/Coronavirus ចុះឈ្មោះសម្រាប់សេចក្តីប្រកាសព័ត៌មាន ឬតាមដានយើងនៅ @lapublichealth
- ចូលទៅកាន់គេហទំព័រជំងឺ COVID-19 របស់ខោនធីនៅ covid19.lacounty.gov
- ពិនិត្យមើលគេហទំព័រ CDC www.cdc.gov/coronavirus

**ការជូនដំណឹងអំពីការឆបោក**

ទទួលព័ត៌មានទាន់ហេតុការណ៍អំពីការឆបោកចុងក្រោយបំផុត និងការប្រុងប្រយ័ត្នដែលអ្នក និងគ្រួសាររបស់អ្នកគួរតែធ្វើ។

- ស្វែងយល់អំពីការឆបោកថ្មីៗពី ការជូនដំណឹងអ្នកប្រើប្រាស់ នៃនាយកដ្ឋានកិច្ចការអ្នកប្រើប្រាស់ និងអាជីវកម្មរបស់ខោនធី Los Angeles
- ចូលទៅកាន់គេហទំព័រ ជំងឺ COVID-19 ការិយាល័យកិច្ចការអន្តោប្រវេសន៍ របស់ខោនធី Los Angeles
- ចុះឈ្មោះសម្រាប់ការតាមដានការជូនដំណឹងអំពីការឆបោក (Fraud Alerts Watch) នៃសមាគមអ្នកចូលនិវត្តន៍អាមេរិក (AARP)
- ចុះឈ្មោះដើម្បីទទួលបានការជូនដំណឹងអ្នកប្រើប្រាស់ របស់គណៈកម្មការពាណិជ្ជកម្មសហព័ន្ធ

**ស្វែងយល់បន្ថែមអំពីការឆបោក និងបញ្ហាអ្នកប្រើសេវាថែទាំសុខភាពសំខាន់ៗផ្សេងទៀត ដោយចូលទៅកាន់ ph.lacounty.gov/hccp**